# I ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ ជស/រកត/០២៩៦/០៨
### ស្តីពីការរៀបចំធ្វើការជំរឿនទូទៅនូវ
### ប្រជារាស្ត្ររបស់ប្រទេសកម្ពុជា

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ

- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួងផែនការ

## ត្រាស់បង្គាប់

## ជំពូក ទី ១

## ការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ និង ការតែងតាំងបុគ្គលិក

**មាត្រា ១ :** ជំរឿនទូទៅនូវប្រជារាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកជាកិច្ចការរបស់ជាតិស្របតាមទម្រង់ការអន្តរជាតិ ត្រូវចាត់ចែងធ្វើក្នុង១០ឆ្នាំម្តង ។

ក្រសួងផែនការ ជាស្ថាប័នទទួលបន្ទុកធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ ដោយមានវិទ្យាស្ថានជាតិស្ថិតិជាអង្គភាពប្រតិបត្តិផ្ទាល់ ។

ការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រនឹងរាប់បញ្ចូលនូវ :

១-កិច្ចប្រតិបត្តិការដំបូងរបស់ការធ្វើជំរឿន :

ក-ការរៀបចំផែនទី

ខ-ការរាប់ និងចុះបញ្ជីលំនៅឋាន

គ-ការធ្វើអង្កេត និងធ្វើជំរឿនសាកល្បង

២-ការធ្វើសំភាសន៍សំរាប់ការធ្វើជំរឿន ។

៣-កិច្ចប្រតិបត្តិការចុងក្រោយរបស់ការធ្វើជំរឿន :

ក-ការធ្វើអង្កេតសំរាប់វាយតំលៃលើការធ្វើជំរឿនដែលបានធ្វើហើយ

ខ-ការអង្កេតផ្សេងទៀតក្នុងករណីចាំបាច់

**មាត្រា ២ :** នាយកវិទ្យាស្ថានជាតិស្ថិតិជានាយកនៃការជំរឿនទូទៅនូវប្រជារាស្ត្រ នឹងត្រូវមានមន្ត្រីបច្ចេកទេស មន្ត្រីរដ្ឋបាលនៃវិទ្យាស្ថានជាតិស្ថិតិ និងមន្ទីរផែនការ ខេត្ត-ក្រុងជួយរាល់ការងារក្នុងការធ្វើជំរឿន ។

**មាត្រា ៣ :** មន្ត្រីបំពេញការងារជំរឿនរួមមានអ្នកសំភាសន៍ស្រង់យកពត៌មាន អ្នកត្រួតពិនិត្យការសំភាសន៍និង ភ្នាក់ងារជំនួយការដល់កិច្ចប្រតិបត្តិការធ្វើជំរឿន ត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងផែនការ តាមការស្នើសុំរបស់នាយកនៃការជំរឿនទូទៅនូវប្រជារាស្ត្រ ។ ការចាត់ចែងនេះអនុវត្តបានតែ ក្នុងអំឡុងពេលធ្វើជំរឿនតែប៉ុណ្ណោះ ។

មាត្រា ៤ : រដ្ឋមន្ត្រីក្រសួងផែនការ មានសិទ្ធិស្នើសុំមន្ត្រីពីបណ្តាក្រសួង ស្ថាប័នសាធារណៈ និងជនសាមញ្ញដើម្បីសហការជួយធ្វើការជំរឿនទូទៅនូវប្រជារាស្ត្រ ។

## ជំពូក ទី ២

## ការរៀបចំធ្វើកិច្ចការជំរឿន

មាត្រា ៥ : កាលបរិច្ឆេទដ៏ជាក់លាក់នៃការផ្តើមធ្វើ និងការបញ្ចប់កិច្ចការជំរឿនព្រមទាំងសេចក្តីរាយល្អិត ពីកិច្ចការនេះនឹងត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងផែនការ ។

មាត្រា ៦ : ត្រូវធ្វើជំរឿនជនគ្រប់រូប ដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា វៀរលែងតែសមាជិកអង្គទូតបរទេស និងក្រុមជនដូចគ្នានឹងអង្គទូតដែរ តាមកិច្ចព្រមព្រៀងដែលត្រូវកំណត់ ឡើង ជាមួយនឹងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៧ : ម្ចាស់លំនៅឋានគ្រប់ប្រភេទ និងអ្នកគ្រប់គ្រងទីកន្លែងនានា ត្រូវអនុញ្ញាតអោយមន្ត្រីបំពេញការងារជំរឿនបានចូលលំនៅឋាន ឬទីកន្លែងរបស់ខ្លួនក្នុងគោលដៅនៃការធ្វើជំរឿន និងអនុញ្ញាត អោយមន្ត្រីទាំងនោះបាន លាបថ្នាំពណ៌ បិទអក្សរ បិទសញ្ញា ឬលេខសំគាល់ នៅតាមកន្លែងចាំបាច់នានា សំរាប់បំរើដល់ការងារធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ ។

មាត្រា ៨ : មន្ត្រីបំពេញការងារជំរឿនទាំងឡាយ អាចសួរមេគ្រួសារ ឬសមាជិកគ្រួសារទាំងអស់ក្នុងពេលធ្វើ ជំរឿន តែតាមសំនួរដូចបានគ្រោងទុកស្រាប់ ហើយនៅតែក្នុងរង្វង់មណ្ឌលដែលបានអនុញ្ញាតអោយប្រតិបត្តិតែប៉ុណ្ណោះ ។

មាត្រា ៩ : ប្រជារាស្ត្រគ្រប់រូបត្រូវតែឆ្លើយ ដោយត្រឹមត្រូវទៅតាមការយល់ដឹងដ៏ប្រាកដរបស់ខ្លួនទៅនឹងសំនួរសំភាសន៍ ដែលមន្ត្រីធ្វើជំរឿនបានសួរដូចក្នុងមាត្រា ៨ សំរាប់ ការធ្វើជំរឿន ។

មាត្រា ១០ : រដ្ឋមន្ត្រីក្រសួងផែនការ អាចប្រកាសតែងតាំងអ្នកគ្រប់គ្រង តាមទីកន្លែងដែលមានលក្ខណៈពិសេស ធ្វើសំភាសន៍អ្នកនៅក្នុងរង្វង់គ្រប់គ្រងរបស់ខ្លួន ។

អ្នកគ្រប់គ្រងតាមទីកន្លែង ពិសេសទាំងនោះមាន :

ក–មេបញ្ជាការយោធា នគរបាល ដែលគ្រប់គ្រងនៅតាមអង្គភាពប្រមូលផ្តុំ ។

ខ–នាយនាវា ដែលគ្រប់គ្រងនៅតាមនាវារបស់ខ្លួន ។

គ-នាយកមន្ទីរពេទ្យវិកលចរិត នាយកមន្ទីរពេទ្យព្យាបាលជម្ងឺទូទៅនាយកពន្ធនាគារ នាយកមជ្ឈមណ្ឌលកែប្រែ នាយកមជ្ឈមណ្ឌលសង្គ្រោះ នាយកមន្ទីរឃុំឃាំងបណ្តោះអាសន្ន ចៅអធិការវត្ត នាយកគ្រឹះស្ថានអប់រំដែលមានមនុស្សរស់នៅ តាមរបៀបប្រមូលផ្តុំ ។

ឃ-អ្នកគ្រប់គ្រងសណ្ឋាគារ អ្នកគ្រប់គ្រងផ្ទះសំណាក់ នាយកមជ្ឈមណ្ឌលសំរាកកាយ ។

ង-អ្នកចាត់ការខ្សែរថភ្លើង អ្នកចាត់ការក្នុងគ្រឹះស្ថានពាណិជ្ជកម្ម អ្នកចាត់ការក្នុងគ្រឹះស្ថានឧស្សាហកម្ម ។

**មាត្រា ១១** : មន្ត្រីដែលគ្មានភារកិច្ចទទួលខុសត្រូវក្នុងការធ្វើជំរឿន មិនមានសិទ្ធិត្រួតពិនិត្យរាល់សៀវភៅ បញ្ជី ឬ សំណៅកត់ត្រា ដែលបានធ្វើឡើងដោយមន្ត្រីបំពេញការងារជំរឿនបានឡើយ។

**មាត្រា ១២** : ពត៌មានជាលក្ខណៈផ្ទាល់ខ្លួន ដែលស្រង់បានក្នុងពេលប្រតិបត្តិការជំរឿនត្រូវបានយកទៅ ប្រើប្រាស់សម្រាប់តែការងារស្ថិតិប៉ុណ្ណោះ ។ ពត៌មានទាំងនោះ ទោះក្នុងករណីណាក៏ដោយនិង មានហេតុផលយ៉ាងណាក៏ដោយ ក៏ពុំត្រូវជូនទៅក្រុមសារពើពន្ធ សាលាជំរះក្តី ឬ អង្គការដទៃណាទៀតបានឡើយ ។ ពាក្យបណ្តឹងទៅសាលាជំរះក្តី ការទារពន្ធអាករដែលសំអាង លើពត៌មានផ្ទាល់ខ្លួនទាំងឡាយដែលស្រង់បានពីប្រតិបត្តិការជំរឿនត្រូវទុកជាមោឃៈ ។

## ជំពូក ទី ៣

## ទណ្ឌកម្ម

**មាត្រា ១៣** : ត្រូវទទួលទណ្ឌកម្មថ្នាក់ទី ២ ដូចមានក្នុងមាត្រា ៤០ ជំពូកទី៥ ក្នុងសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ចំពោះ :

ក-មន្ត្រីបំពេញការងារជំរឿនទាំងឡាយណា ដែលរាជការបានចាត់អោយជួយធ្វើកិច្ចការជំរឿន ហើយមិនព្រមបំពេញមុខការរបស់ខ្លួន ឬ មិនព្រមបំពេញមុខការរបស់ខ្លួនអោយបានចប់សព្វគ្រប់ ឬ ធ្វើការនោះដោយធ្វេសប្រហែលមិនសមហេតុសមផល ឬ មិនប្រតិបត្តិការបទបញ្ញត្តិណាមួយ ដែលបានបង្កើតមកសំរាប់អនុវត្តន៍ព្រះរាជក្រឹត្យនេះ ។

ខ-មន្ត្រីបំពេញការងារជំរឿនទាំងឡាយណា ដែលតំរោងសួរដោយចេតនា ឬ បំភ្លៃសំនួរខុសពីសំនួរគ្រោងទុក ឬ បញ្ចូនពត៌មានមិនពិតដោយចេតនាមកទីចាត់ការជំរឿន ។

គ-មន្ត្រីបំពេញការងារជំរឿនទាំងឡាយណា ដែលលួចប្តូរឯកសារ (ក្រដាសថាសកុំព្យូទ័រ ខ្សែអាត់ ) ប្តូរពត៌មានសំងាត់ ធ្វើអោយខូចខាត ឬ បាត់បង់ឯកសារជំរឿន ។

ឃ-មន្ត្រីបំពេញការងារជំរឿនទាំងឡាយណា ដែលលួចបញ្ចេញពត៌មានដែលខ្លួនបានទទួលពីការធ្វើជំរឿន ។

**មាត្រា ១៤** : ត្រូវទទួលពិន័យជាប្រាក់ពី ៥.០០០ រៀល (ប្រាំពាន់រៀល) ដល់ ៥០០.០០០ រៀល (ប្រាំរយ ពាន់រៀល ) និងតម្រូវអោយអនុវត្តតាមមាត្រា ៧ និង មាត្រា ៩ នៃព្រះរាជក្រឹត្យនេះ ចំពោះ :

ក-ជនណាអោយចម្លើយខុសដោយចេតនា ឬមិនព្រមឆ្លើយនូវសំនួរ ដែលមន្ត្រីបំពេញការងារជំរឿនបានសួរ ។

ខ-ម្ចាស់ ឬអ្នកគ្រប់គ្រងលំនៅឋាន និងមូលដ្ឋានទាំងឡាយណាដែល មិនព្រមអនុញ្ញាតអោយមន្ត្រីបំពេញការងារជំរឿន ចូលលំនៅឋាន ឬមូលដ្ឋានខ្លួនគ្រប់គ្រង ដើម្បីស្រង់យកពត៌មានសំរាប់ការធ្វើជំរឿន ។

គ-ជនទាំងឡាយណាដែលបានមកធ្វើអោយបាត់ ឬ ធ្វើអោយខូចដោយចេតនានូវអក្សរសញ្ញា ឬលេខដែលមន្ត្រីបំពេញការងារជំរឿនបានចាត់ចែងគូរ បិទ ឬ ព្យួរទុកសំរាប់ការងារជំរឿន ។

ឃ-ជនទាំងឡាយណាដែលចូលដោយគ្មានការអនុញ្ញាតទៅក្នុងទីកន្លែងរក្សាទុកឯកសារជំរឿន ។

ង-ជនទាំងឡាយណា ដែលបង្កការលំបាក ឬរារាំងមិនអោយមន្ត្រីបំពេញការងារជំរឿនបាន បំពេញភារកិច្ចរបស់គេដោយសុវត្ថិភាព ។

## ជំពូក ទី ៤

## ថវិកាក្នុងការធ្វើជំរឿន

**មាត្រា ១៥** : ថវិកាក្នុងការរៀបចំធ្វើជំរឿនទូទៅនូវប្រជារាស្ត្រត្រូវស្ថិតក្នុងគំរោងថវិកាជាតិ ។

រដ្ឋមន្ត្រីក្រសួងផែនការត្រូវគ្រោងទុក និងចាត់ចែងប្រើប្រាស់ថវិកាជាតិ ឬ ថវិកាជំនួយអន្តរជាតិសំរាប់កិច្ចការនេះ ។

## ជំពូក ទី ៥

## អវសានបញ្ញត្តិ

**មាត្រា ១៦** : នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី ២ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ១៧** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

បានបង្គំទូលថ្វាយ និង ជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

រដ្ឋមន្ត្រីក្រសួងផែនការ

ហត្ថលេខា

**ជា ចាន់តូ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រី ២

ព្រះហស្តលេខា ហត្ថលេខានិងត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

## ព្រះរាជក្រឹត្យជស./រកត/០៣៩៦/០៩

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន រាជហរិវង្ស

## ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ